# er0gGaemAEqqÿ

**That crazy dog Amao**

**SAUY Lauth**

sUy.LÚ

លោកកើតនៅថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩៨១នៅភូមិប៉ុកប៉ែន ឃុំមានជ័យ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។ លោកបានបញ្ចប់ការសិក្សាថ្នាក់ទុតិយភូមិនៅឆ្នាំ២០០២។ ប្រលោមលោកខ្នាតខ្លីរឿង «អាម៉ៅឆ្កែឆ្កួត» ជាស្នាដៃដំបូងរបស់លោក។

ថ្ងៃត្រង់ក្ដៅហែងបណ្ដើរកូនបែកផ្សែងព្រិចៗ បរិយាកាសស្ងាត់អោយឈឹង ឮតែសំលេងសត្វឃ្មុំ អែអ្វូត តាវៅនិងសត្វបក្សាបក្សីផ្សេងៗជាច្រើនទៀតយំឮល្វើយៗ លាយជាមួយសំលេងកង្កែបកូនគ្រាតយំឮខ្សាវៗ ហាក់ដូចជាគ្មានកំលាំងកំហែងអ្វីសោះ។ មើលទៅដូចជាមិនពេញចិត្តចំពោះព្រះអាទិត្យ ដែលឆ្លៀតឱកាសពេលខ្លួនបានមកគ្រប់គ្រងផែនដីបញ្ចេញអំនាចដ៏ក្ដៅគគុកមកលើធម្មជាតិអោយខ្លបខ្លាច។ ម្យ៉ាងទៀតប្រហែលជាអន់ចិត្តចំពោះពពក ដែលនៅសំងំស្ងៀមក្បែរជើងមេឃធ្វើព្រងើយ មិនហ៊ានចេញមុខមកសំរាលនូវសេចក្ដីទុក្ខរបស់ខ្លួន ហើយសុខចិត្តឈរញញឹមបញ្ចើចបញ្ចើដើម្បីបញ្ឆោតអនក្ខរជនដោយមានគំនិតថាអនក្ខរជនកំពុងតែយល់និងជឿជាក់លើខ្លួនថា ខ្លួនជាមេដឹកនាំដែលតែងតែជួយលើកទឹកចិត្តដល់ពួកគេ គ្រប់ពេលវេលា។ ហើយរឿងមួយទៀតនោះ ប្រហែលជាអន់ចិត្តចំពោះព្រះពិរុណពន់ពេកដោយដឹងថាខ្លួនអាចសង្គ្រោះសត្វលោកបាន តែបែរជាខំលាក់កំបាំងយកត្បែរចខ្លួន មិនដែលយកចិត្តទុកដាក់គិតគូរពីសុខទុក្ខរបស់សភាវតូចតាច ដែលកំពុងតែក្ដៅក្រហាយ។ យូរៗគេឃើញទឹកភ្លៀងធ្លាក់មកមួយប្រាវ ផ្គរលាន់មួយក្ដួង ជាការបញ្ជាក់ថាព្រះពិរុណសែនអាណិតអាសូរចំពោះជីវិតតូចតាចរហូតដល់ស្រក់ទឹកភ្នែក ហើយបេះដូងលោតខុសចង្វាក់លាន់ឮរំពងមេឃនេះជាការយល់ឃើញនៃសភាវមួយក្រុម។ ប៉ុន្តែអ្នកមួយភាគទៀតយល់ថាវាជាសំលេងជល់កែវស្រា ហើយទទួលទានមិនអស់ ទើបជះមកលើផែនដី ប្រយោជន៍កុំអោយពុកគូទកែវតែប៉ុណ្ណោះ។ ភាពឯកាយូរៗទៅ ធ្វើអោយអ្នកខ្លះយល់ថា ព្រះពិរុណប្រហែលជាស្ថិតនៅក្រោមអំនាចនៃព្រះអាទិត្យផងក៏មិនដឹង ចំនែកអ្នកខ្លះទៀតហ៊ាននិយាយដល់ថាព្រះពិរុណប្រហែលជាលក់ក្បាលអោយព្រះអាទិត្យទៀតផង ទើបពេល

នេះមិនត្រឹមតែភ្លេចកាតព្វកិច្ចទេ ថែមទាំងក្បត់កាតព្វកិច្ចទៀត។ ដូច្នេះអ្វីដែលពួកគេត្រូវគិតបន្ត នោះគឺ តើបានដឹងណាទុកកប់សពរបស់ខ្លួន។ បរិយាកាសពណ៌ស្រអាប់លាយឡំជាមួយជំនោរដែល យូរក៏បក់មកម្តង តែគ្មានភាពត្រជាក់ធ្វើអោយអ្វីៗទាំងអស់នៅស្ងៀមមិនកំរើក។ ទោះបីផ្លៀត រង្គើតិចក៏ដោយ តែមើលទៅដូចជាគ្រាន់តែជាការសំរួល ដើម្បីបន្ថយការស្ពឹកស្រពន់ប៉ុណ្ណោះ។ ស្ថានភាពគ្មានមនុស្សដើរ គ្មានចតុប្បាទបោល ឬគ្មានបក្សីហើរ បានបំផុសចេញជាទិដ្ឋភាពមួយ ដែលគួរអោយសង្វេគ។ ក្រោយពេលអ្នកផងទាំងពួងទៅផ្ទះអស់នៅសល់តែឧបករណ៍កសិកម្ម ខ្លះៗ ដែលគេទុកបំរុងធ្វើស្រែពេលភ្លៀងធ្លាក់។

អាម៉ៅបោលងក់ៗកាត់វាលស្រែខៀវខ្ចីផ្នែកបាតអូរ វាបានឃើញស្រូវកំពុងប្រជែងគ្នាលូតលាស់ យ៉ាងសប្បាយរីករាយវាក៏គិតក្នុងចិត្តថា ÷

-ឱស្រូវដ៏ខៀវខ្ចីអើយ មើលទៅអ្នកដូចជារីករាយណាស់ តើអ្នកធ្លាប់ក្រលេកមើលជុំវិញខ្លួនដែរឬទេ ថាតើមានអ្វីកើតឡើងខ្លះ? ឬក៏អ្នកមិនអាចស្មានតិចៗអោយដឹងថា តើពេលខាងមុខមានអ្វីកើតឡើង ចំពោះអ្នក? បើសិនជាគ្មាន ប្រហែលជាមកពីពេលនេះមនុស្សកំពុងតែថែបំប៉នអ្នកហើយមើលទៅ។ អាម៉ៅងើបមុខមើលមេឃដោយនៅនឹងមាត់របស់វាមានពាំអណ្តើកផង មួយសន្ទុះក្រោយមកវាដាក់ មុខចុះវិញដោយបិទភ្នែក ដកដង្ហើមធំហើយបន្តគំនិតថា ÷

-ណ្ហើយ! ចាត់ទុកថាសុភាសិតហុចរបស់ស្រណោះដែរគេថាខុសទៅចុះ។

គិតហើយវាបន្តដំនើរទៅមុខទៀត រហូតផុតស្រូវខ្ចីហើយឡើងដល់ផ្នែកមាត់បឹង វាបានឃើញស្រូវ ជាច្រើនលើសលប់មានពណ៌ក្រហមខ្មោចឈរឆ្កឹងៗប្រកបដោយរាងកាយស្វិតស្រពោន វាគ្រលៀស ភ្នែកមើលជុំវិញខ្លួនដោយកាយវិការយឺតៗ ទើបមានគំនិតថា ÷

-ហ៊ឺ! ហេតុតែគ្នាមិនអាចផ្តល់ផលបានច្រើនទើបត្រូវគេបោះបង់ចោលអោយនៅឯកាហាក់ដូចជា គ្មានមេគ្មានកើយ ទុកឱកាសអោយស្មៅសក់សេះ កណ្តុរនិងសត្វចង្រៃផ្សេងៗលួចប្លន់តាមអំពើចិត្ត ឱលោកបងស្រូវអើយ ពេលនេះខ្ញុំមិនដឹងធ្វើដូចម្តេចដែរ ព្រោះកាលពីគ្រាមុនគេយកជីមកដាក់ អ្នកក៏ដឹងដែរថានឹងធ្វើអោយព្រះធរណីមានគ្រោះថ្នាក់ ពេលនោះអ្នកមិនត្រឹមតែសប្បាយចិត្តក្នុងការ ទទួលប៉ុណ្ណោះទេ ប្រហែលជាអ្នកភ្លេចគិតថាព្រះធរណីជាអ្នកបំបៅអ្នកទៀតផង។ ពេលនេះអ្នក ស្រែក គឺស្រែកដាក់ត្រចៀកព្រះធរណី ខ្ញុំល្វីងមុខអាណិតអ្នកណាស់ព្រោះពេលនេះ ព្រះធរណីមាន ជំងឺទៅហើយ។

បន្ទាប់ពីនេះ វាឡើងដល់ទីទួលដែលគ្មានស្រូវ ហើយវាមានអារម្មណ៍ថា ព្រះវាយោហាក់ដូចជា បញ្ចេញសកម្មភាពម្តងៗ ប្រយោជន៍បន្ថយភាពតានតឹង។ ត្បិតតែយ៉ាងនេះបានធ្វើអោយអាម៉ៅ

ពេញចិត្តរហូតដល់មានចិត្តកោតសសើរ តែការសសើរនេះមិនយូរប៉ុន្មាន ទឹកមុខបញ្ជាក់ពីសេចក្តីអស់សង្ឃឹមក៏កើតឡើងសាជាថ្មី វាក៏បន្តដំនើរបណ្តើរបង្កគំនិតបណ្តើរ ៖
-សូម្បីតែព្រះវាយោក៏គ្មានពាក្យថាឯករាជ្យដែរ។ ហេតុអ្វីបានជាម្នាក់ៗចូលចិត្តពាក់ស្បែកមុខកិត្តិយសចំពោះកែវភ្នែកអនក្ខរជនម្លេះ!
កំពុងតែលង់ស្លុងក្នុងអារម្មណ៍ស្រាប់តែក្រហែងបានត្របាក់ជើងអាម៉ៅអោយជាប់ដួល។ វាងើបឡើងហើយគ្រវីក្បាលថែមទាំងរអ៊ូក្នុងចិត្តថា ៖
-ទីបំផុត ការពិតនៅតែជាការពិត ហើយការមិនពិតនៅតែមិនពិត។ ពេលនេះអ្នកសើចដាក់ខ្ញុំហើយអ្នកនៅឆ្លៀតខាំជើងចំអកអោយខ្ញុំទៀត ឥឡូវខ្ញុំមិនតបនឹងអ្នកទេ ចាំបន្តិចទៀតអ្នកនឹងយល់ដោយបែកបញ្ញា នង្គ័ល រនាស់នៅជិតអ្នកនេះ អ្នកសប្បាយចិត្តទៅ។ តែខ្ញុំសង្ឃឹមថាអ្នកហាមាត់ពេលនេះមិនមែនដោយសារស្រេកទឹក ឬជាប់ថ្គាមនោះទេ។
កំពុងតែលង់លក់នៅក្នុងអារម្មណ៍ដែលជោគជាំដោយសេចក្តីសង្វេគ ស្រាប់តែឮសំលេងរំពងមជ្ឈដ្ឋានចេញពីចុងពោធិ៍ធំមួយ។ អាម៉ៅមានកំលាំងព្រឺស វាមានគំនិតថាសាច់ញាតិរបស់វា កំពុងតែកញ្ច្រោលហៅកញ្ច្រៀវស្វាគមន៍ចំពោះខ្លួនដោយសេចក្តីកក់ក្តៅ វាក៏ពាំអណ្តើកដែលវាខាំពាំពីមុនមក មិនខ្លាចធ្ងន់រត់សំដៅដើមពោធិ៍នោះ។ ពេលទៅដល់ វាភ្ញាក់ព្រើតហើយគិតក្នុងចិត្តទៀតថា ៖
-អូ! មានសត្វស្រាំង សត្វឱម៉ាល់ ឆ្កែញ៉ាំង ស្រមោចលីង ជីងចក់ តុកកែ ឃ្មុំនិងបក្សាបក្សីច្រើនរាប់មិនអស់ ពួកអ្នកសុទ្ធតែជាពូជខុសៗគ្នា ប៉ុន្តែនៅតែមានចិត្តច្រៀងលេងកំសាន្តទៀត គួរអោយសសើរមែនទែន។ តែពួកអ្នកគ្មានសំណាងបានរស់នៅក្បែរសត្វមានសតិបញ្ញា និងប្រកបដោយវិចារណញ្ញាណដូចរូបខ្ញុំទេ។
អាម៉ៅឈរសំឡក់ពួកសត្វទាំងនោះចរចា និងបញ្ចេញសកម្មភាពចិញ្ចឹមជីវភាពគ្រួសារ។ វាសប្បាយ និងពេញចិត្តណាស់ទើបវារៀនធ្វើការវិភាគក្នុងចិត្តថា ៖
-តែនឹកៗទៅខ្ញុំចេះតែចង់សសើរពួកអ្នក ត្បិតតែពួកអ្នកនិងខ្ញុំ ត្រូវគេដាក់ងារថាជាសត្វគ្មានវិចារណញ្ញាណសំរាប់ពិចារណារកខុសត្រូវក៏ដោយ តែបើតាមខ្ញុំគិតទៅ អ្វីដែលមនុស្សលើសយើងនោះគឺឈ្នានីស អំនួត លោភៈឈ្លោះប្រកែកគ្នានោះឯង។
កំពុងតែសប្បាយក្នុងការកោតសសើរ ស្រាប់តែជំនោរបានបណ្តែតខ្លួនមកបបោសអង្អែលប្រាណអាម៉ៅអោយកើតសេចក្តីសុខខុសពីធម្មតា។
-ហា! គ្រជាក់ណាស់មានកំលាំងម្លេះទេ ខ្យល់អោយត្រសៀក ម្លប់ក៏ត្រឈៃពិតជាអ្នកមើលថែប្រកបដោយព្រហ្មវិហារធម៌មែន។ ព្រះពុទ្ធចារពិតជាមិនខុសសោះ បរមសុខពិតជាផលនៃសេចក្តីល្អមែន។

ដោយព្រោះកាលបានកំនត់ពេលវេលាយ៉ាងច្បាស់លាស់ អាម៉ៅពាំអណ្តើកចេញពីដើមពោធិ៍ ដោយចិត្តសោកស្តាយ តែការពិតបានប្រាប់វាថា វាត្រូវតែចេញ ហើយអ្វីដែលវាចង់បាននោះមានតំលៃត្រឹមតែពាក្យថាសោកស្តាយតែប៉ុណ្ណោះ។ ដើម្បីបន្លប់ទឹកចិត្តស្រណោះស្រណោកនេះ គឺមានតែវាចារចុងក្រោយថា៖

-ខ្ញុំចង់អោយនៅជុំវិញខ្ញុំមានអ្វីៗដូចពួកអ្នកណាស់។ តែធ្វើម្តេចទៅ បើខ្ញុំកើតមកពូជជាសត្វតើមានសមត្ថភាពឯណានឹងចាត់ចែងរឿងនេះទៅ។ កុំថាឡើយដល់ថ្នាក់ហ្នឹង សូម្បីតែចេញវាចាទៅក៏មិនដឹងជាមាននរណាគេស្តាប់និងធ្វើតាមដែរ។ អេ! កុំទៅគិត ទ្រាំៗទៅទំរាំដល់ថ្ងៃស្លាប់ ក្រែងកើតជាតិក្រោយមានវាសនាជាងនេះ។

ក្រោយពីអស់ចិត្តពីដើមពោធិ៍ហើយអាម៉ៅក៏ពាំអណ្តើកធ្វើដំនើរទៅផ្ទះ វារត់បណ្តើរចេះតែលួចញញឹមបណ្តើរ ព្រោះវាកំពុងតែស្រមៃឃើញថា មេរបស់វានឹងមានកំលាំងជាស្បើយពីរោគាមិនខានបន្ទាប់ពីបានស៊ីអណ្តើក តែមិនទាន់ដល់ផ្ទះត្រឹមត្រូវផង ស្រាប់តែវាឮពេញទាំងត្រចៀកវាថា៖

-ពុកៗអាម៉ៅពាំអណ្តើកមកហើយ ថ្ងៃនេះពិតជាឆ្ងាញ់មិនខានឡើយ។

អាម៉ៅជ្រុះថ្លើមក្តុកទន់ជង្គង់លត់ទៅដីសំដែងនូវសេចក្តីខកចិត្ត ចំនែកម្ចាស់វាមិនត្រឹមតែមិនយល់អំពីទំហំទុក្ខរបស់អាម៉ៅទេ បែរជាមានគំនិតច្រឡំថែម គាត់ក៏ប្រញាប់តបទៅអាម៉ៅថា៖

-ទេមិនបាច់ដល់ថ្នាក់ហ្នឹងទេអាម៉ៅឯងមិនបាច់ថ្វាយបង្គំអញទេ។

អាម៉ៅព្រុសវ៉ូសៗវាចង់និយាយថា ៖

-អយុត្តិធម៌ណាស់ៗ ទេខ្ញុំមិនអោយទេ។

វាចង់ទុកអោយមេវាស៊ី ចំនែកម្ចាស់នៅតែគិតច្រឡំថែមទៀតថា៖

-ទេមិនបាច់អរគុណអ្វីទេ អញទេដែលត្រូវអរគុណឯង ថ្វីត្បិតតែឯងជាសត្វ តែអញទុកដូចកូនចៅអញហ្នឹង។

បន្ទាប់ពីបានអណ្តើកហើយ ក្នុងគ្រួសារសែនសប្បាយចិត្តណាស់ សសើរមិនដាច់ពីគុណសម្បត្តិអាម៉ៅ។ ការចាត់ចែងធ្វើម្ហូបរួចស្រេចបាច់ហើយ ក៏ចាប់ផ្តើមទទួលទាន។

មេឃស្រលះធេងពេលថ្ងៃត្រង់ ប្រែជាមានពពកខ្មៅជាបម្លយរំពេច ឆ្លៀតឱកាសព្រះអាទិត្យមិននៅព្រះពិរុណក៏ប្រញាប់ប្រញាល់ស្រវេស្រវាបញ្ចេញសកម្មភាពគ្រប់គ្រងផែនដីភ្លាមៗដែរ មើលទៅដូចជាឥតក្រែងរអែងចិត្តចំពោះព្រះអាទិត្យទាល់តែសោះ ហើយទំលាក់ខ្លួនពីលើវេហាយ៉ាងសប្បាយរីករាយមកលើផែនដី។ បរិយាកាសត្រជាក់គួរអោយចង់រស់នៅ រុក្ខជាតិភាគច្រើនញញឹមពព្រាយតែអ្នកខ្លះនៅមិនទាន់ទុកចិត្តនៅឡើយគឺត្រឹមតែបានលួចញញឹមតែប៉ុណ្ណោះ។ ថ្វីត្បិតតែធម្មជាតិ

ពេលនេះសុទ្ធតែគួរអោយស្រលាញ់សំរាប់ជីវិតលើផែនដីក៏ពិតមែន តែសំរាប់អាម៉ៅហាក់ដូចជាគ្មានន័យខ្លឹមសារអ្វីទាល់តែសោះ អ្វីដែលសំខាន់សំរាប់វាពេលនេះ គឺការស្ដាយស្រណោះអណ្ដើកដែលវាគិតថាទុកអោយតែមេវាស៊ី។ កំពុងតែស្លុងក្នុងអារម្មណ៍ ស្រាប់តែវាឮសំលេងគំហកមួយថា÷

-មុខដូចពួកឯងសមតែស៊ីឆ្អឹងដូចឆ្កែទើបត្រូវចិត្ត។

អាម៉ៅភ្ញាក់ព្រើត ផ្ទៀងត្រចៀកស្ដាប់កូនៗឈ្លោះប្រកែកដណ្ដើមសាច់អណ្ដើកគ្មានរញ៉េរញ៉ៃរញ៉ាចឥតឈប់។ ពេលនោះវាបានឮបុរសជាឪពុកបន្លឺងសរសែក ហើយស្រែកបន្តទៀតថា÷

-ស្អីពួកឯង! ពេលស៊ីឈ្លោះគ្នាមើលតែឆ្កែ ដោយសារតែឆ្កែវាចូលចិត្តខាំគេដើម្បីអោយម្ចាស់វាចូលចិត្តកោតសសើរដើម្បីតែលាភសក្ការៈហ្នឹងហើយ ទើបសង្គមវានៅតែឆ្កែ។

ទោះបីជាឪពុកព្យាយាមហាមឃាត់យ៉ាងណាក៏ដោយ ក៏កូនៗមិនព្រមឈប់ ចេះតែតវ៉ាថាបើមិនស្មើភាពគ្នាទេពួកវាមិនសុខចិត្តឡើយ ហើយម្នាក់ៗនៅតែប្រកាន់ពាក្យថាខ្លួនត្រូវគ្រប់ៗគ្នា។ ដោយសារសភាពការណ៍កាន់តែតានតឹងទៅព្រោះហេតុគ្មានអ្នកចុះចាញ់ ទើបបុរសជាឪពុកស្រែកគំរាមថា÷

-បើកូនៗនៅតែមិនឈប់ឈ្លោះគ្នាទៀត ពុកនឹងបញ្ជូនពួកឯងអោយទៅធ្វើកញ្ជះគេ អោយគេជេរព្រឹកជេរល្ងាចដូចឆ្កែមិនខាន។

អាម៉ៅឈឺចិត្តញ័រខ្លួនទទ្រើតស្ទើរទ្រាំពុំបាន បើតាមចិត្តខឹងចង់តែស្ទុះទៅខាំអោយរហែកមាត់ដើម្បីជាការសងសឹងចំពោះពាក្យតិះដៀលដែលគួរអោយចុកឈាម។ តែដោយសំឡឹងទៅឃើញមេកំពុងជាប់ច្រវាក់ទើបវាគិតបន្ធូរអារម្មណ៍ថា÷

-ណ្ហើយទ្រាំចុះ តើអោយធ្វើម្ដេចទៅក្រៅពីការទ្រាំ បើទៅប្ដឹងក៏គង់មិនឈ្នះគេ ព្រោះតុលាការព្រះរាជអាជ្ញា មេធាវីឬអ្នកធ្វើការគ្រប់ជាន់ថ្នាក់សុទ្ធតែជាមនុស្ស។ ហះៗ! បើនិយាយថាគេកាត់អោយឆ្កែឈ្នះមនុស្ស ដូចជារឿងដែលគួរអោយអស់សំណើច។ យី! ថ្ងៃនេះម្ដេចក៏ម្ចាស់ខ្ញុំមិនអោយបាយខ្ញុំស៊ីអញ្ចឹង?

-កុំជះអោយឆ្កែស៊ីវាមិនដែលបានសាច់លក់ទេ។

-ពុកមើលបងប្រុសចុះ ដើម្បីចង់ឈ្នះនាំរឿងហេតុដល់ឆ្កែ ពេលនេះសូម្បីតែឆ្អឹងនិងបាយផ្អូមក៏គាត់មិនអោយវាស៊ីដែរ។

បងប្រុសលើកវែកវាយក្បាលប្អូនឮផែស ប្អូនទ្រហោយំនទៀលលើគ្រែធាក់ចានឆ្នាំងបែកខ្ទាយ។ អាម៉ៅសប្បាយចិត្តណាស់ព្រោះវាឃើញសាច់អណ្ដើកធ្លាក់មកដី វាក៏ស្ទុះទៅវឹង តែវាមិនទាន់នឹងបានស្គាល់ក្លិនផង សំលេងខ្ទរស្ទើរបែកក្រដាសត្រចៀកបានបន្លឺឡើង។

-ឆ្កែ!

អាម៉ៅខឹងឆេវឆ្ងាំលែងបាន វាក៏ស្រែកវ៉ូសៗមិនឈប់ហើយខ្លាំងឡើងៗ។ បុរសជាម្ចាស់ដឹងថាអាម៉ៅប្រាជកជាចង់តវ៉ាទើបគាត់ពោលចំអកថា ÷

-គួរអោយស្តាយណាស់ដោយឯងជាឆ្កែ ព្រះជាម្ចាស់ ទេវតា ព្រះឥន្ទ្រ ព្រះព្រហ្មបង្កើតឯងមកសំរាប់តែបំរើអញតែប៉ុណ្ណោះ។ ឬមួយឯងចង់ធ្វើបដិវត្តន៍? បើអញ្ចឹងឯងមើលទៅក្រោយមើល៍!

អាម៉ៅក្រលេកមើលទៅក្រោយ វាស្រយុតចិត្តណាស់នៅពេលដែលវាឃើញកាំបិត ដាវ ស្នួ ស្នា ដែលជាគ្រឿងសំរាប់ប្រល័យ ហើយរបស់ទាំងនោះវាគ្មានសមត្ថភាពប្រើទាល់តែសោះ វាដាក់មុខចុះបង្ហូរទឹកភ្នែកហើយដើរទៅរកមេដោយក្តីអស់សង្ឃឹម ទៅដល់មុខមេ មេកំពុងតែអណ្តឺតអណ្តកស្ទើរតែរកខ្យល់ដកដង្ហើមពុំបាន។ អាម៉ៅខ្លោចចិត្តអាណិតមេវាណាស់ វាក្រាបពីមុខមេទាំងចុកឈាម មួយសន្ទុះក្រោយមក ដោយទឹកចិត្តអាណិតមេវាក៏បែកគំនិតថា អោយម្ចាស់វាយកទៅពេទ្យ វាក៏ស្ទុះទៅភ្លាមដោយអារម្មណ៍មិននៅក្នុងខ្លួន វាលើកជើងមុខដាក់លើគ្រែមិនទាន់ស្រួលបួលផងស្រាប់តែវាឮសំលេងសង្កៀតធ្មេញស្ទើរបាក់ថា ÷

-ឆ្កែ!

សំលេងស្រែកឮដល់ត្រចៀកអាម៉ៅកាលណា អង្រែបុកគ្រឿងក៏មកដល់ក្បាលវាកាលនោះដែរ។

-បុណ្យមិនទាន់ដល់ទេអាវ៉ា ថយចេញភ្លាមអញស្អុយក្លិនឯងណាស់ មើលចុះជើងឯងសុទ្ធតែដីប្រយ័ត្នប្រលាក់គ្រែអញនែ! បើឯងចង់ឡើងលើគ្រែ ម្តេចមិនកើតក្នុងត្រកូលមនុស្សទៅអាពូជខ្លៅ!

អាម៉ៅឆ្អែតចិត្តដើរទៅរកមេដោយអស់សង្ឃឹមម្តងទៀត ទៅដល់ជិតមេនៅពីក្រោយខ្នងវាស្រាប់តែឮសំលេងច្រើង! ផែស! ការប្រតាយប្រតប់បានកើតឡើងជាសង្គ្រាមស៊ីវិលមួយ លែងស្គាល់ពាក្យថាបងប្អូន។ គ្រែបាក់ជើងដួលប្រាវធ្វើអោយបាស់ជើងបាស់ដៃមានរបួសឈាមរលាក់រាងៗខ្លួន ដោយសារឪពុកឃាត់កំញ៉ោញខ្លាំង អំពើហិង្សាត្រូវបានប្តូរជាការចរចាវិញ តែការចរចានៅតែគ្មានប្រយោជន៍សំរាប់ដោះស្រាយទំនាស់សោះ ហើយម្នាក់ៗនៅតែអះអាងថាខ្លួនត្រូវដដែល ប្រកាន់មាំនូវគោលជំហដាច់ណាត់។ ឪពុកអស់មធ្យោបាយក៏នឹកឃើញការវិនិច្ឆ័យមួយដែលសង្ឃឹមថាកូនៗអាចទទួលបាន គាត់ក៏ប្រាប់ថា ÷

-កូនៗស្តាប់ឪ បើកុំតែអាម៉ៅវារកអណ្តើកមកអោយកូនស៊ី ក៏គ្មានរឿងបែបនេះដែរ ពិសេសជំលោះនេះកើតឡើងដោយសារស៊ីមិនឆ្អែត មធ្យោបាយមានតែមួយគឺសំលាប់អាម៉ៅយកសាច់អោយកូនស៊ីអោយបានឆ្អែត។

អាម៉ៅភ្ញាក់ព្រើត ភាពភ័យរន្ធត់ក៏កើតមានឡើង អាម៉ៅរត់ចុះរត់ឡើងជុំវិញមេ ហើយចេះតែឆ្លៀតឱកាសខាំច្រវ៉ាក់ តែអនិច្ចាវាមិនអាចដាច់បានទេ។ ម្ចាស់វាចេះតែដេញវាយផងកាប់ផងត្រូវខ្លះ

ខុសខ្លះធ្វើអោយរបួសឈាមហូររលាក់ប្រលាក់រដិបរដុបស្ទើរគ្រប់ទីកន្លែង ដោយទ្រាំពុំបាននឹងការឈឺចាប់ ម្យ៉ាងគិតថាមេវាកំពុងតែមានជំងឺក្នុងខ្លួនពោរពេញទៅដោយមេរោគប្រហែលជាម្ចាស់វាលើកលែងមិនសំលាប់ទេ វាក៏រត់បាត់ទៅធ្វើអោយគ្រួសារម្ចាស់ឆ្កែខឹងខ្លាំងណាស់ ហើយក៏សំលាប់មេវាចោលជំនួសអាម៉ៅទៅ។ មេឃនៅតែភ្លៀងហាក់ដូចជាកំពុងជួយលាក់កំបាំងរឿងនេះមិនអោយអ្នកផងដឹង ដើម្បីជាការដាក់ទារុណកម្មចំពោះអាម៉ៅអញ្ចឹង។ ពេលនេះបុរសម្ចាស់ឆ្កែកំពុងតែពន្លាត់ស្បែកមេអាម៉ៅ ឯកូនៗនាំគ្នាជួសទឹកភ្លៀងលាងឈាម។

ចំនែកមេភូមិដោយឮដំណឹងល្មៀងៗថាក្រុមចោរប្លន់នឹងចូលធ្វើសកម្មភាពឆាប់ៗនេះ គាត់ក៏ឆៀងចូលមកមើលមេអាម៉ៅទាំងភ្លៀង ដោយមានគំនិតថាក្រែងបានជាស្បៀយនឹងបាននាំហ្វូងឆ្កែការពារភូមិប្រឆាំងសត្រូវ។ នៅពេលប្រទះឃើញរឿងដែលប្លែកពីគោលបំនង គាត់មិនត្រឹមតែមិនស្តាយស្រណោះប៉ុណ្ណោះទេ គាត់ស្រាប់តែស្រក់ទឹកមាត់ឆេវហើយធ្វើជាភ័យថា ÷

-អ៎ា! លោកបងម្តេចក៏ធ្វើយ៉ាងនេះ ប្រជាជនភូមិយើង ឬប្រជាជនភូមិដទៃនៅក្នុងឃុំប្រាកដជាមិនព្រមទេ ខ្ញុំជឿថាប្រាកដជាមានរឿងច្របូកច្របល់ ព្រោះទាំងមនុស្សទាំងឆ្កែនៅគ្រប់ភូមិសុទ្ធតែដឹងថា មានតែអាម៉ៅនិងមេវាទេ ដែលអាចធ្វើអោយឃុំយើងមានសន្តិភាព។

ម្ចាស់ឆ្កែដើរមកជិតមេភូមិហើយខ្សឹបស្ងាត់ៗថា :

-លោកបងអញ្ជើញទៅចុះចាំខ្ញុំអោយពាក់កណ្តាល ថ្ងៃស្អែកពេលមានឆ្កែមកតវ៉ាយ៉ាងហោចណាស់ក៏មានងាប់ពីដប់ទៅហាសិបក្បាលដែរ នៅពេលនោះបងចង់ស្រវឹងប្អូនដប់ដងក៏មិនអស់ដែរ។

-ខ្ញុំខ្លាចតែអ្នកស្រុកមិនសុខចិត្ត។

-លោកបងស្រេចតែខ្ញុំ បងចាំតែបោះត្រាលើលិខិតបញ្ជាក់ទៅបានហើយ។

ក្រោយពេលចរចាត្រូវគ្នាហើយ មេភូមិនិងម្ចាស់ឆ្កែបាននាំគ្នាផឹកស្រាក្លែមសាច់ឆ្កែយ៉ាងសប្បាយរីករាយ។

ថ្លែងពីអាម៉ៅពេលវាដឹងថាមេវាស្លាប់ហើយ វាក៏រត់រកអ្នកស្រុកអោយជួយពេញទាំងឃុំ តែអ្នកស្រុកគេមិនចេះស្តាប់ភាសាសត្វទេក៏ចេះតែធ្វើជាមិនដឹងមិនឮទៅ ហើយអ្នកខ្លះថែមទាំងស្រែកបញ្ឆិនទៀតផង។ មានតែឆ្កែដូចគ្នាទេដែលយល់ចិត្តអាម៉ៅ រឿងរ៉ាវអាម៉ៅធ្វើអោយផ្អើលឆ្កែពេញទាំងឃុំអ្នកស្រុកខ្លះឆ្ងល់ខ្លាំងណាស់ក៏ប្រមូលគ្នាមកផ្ទះអាម៉ៅ មកដល់ផ្ទះអាម៉ៅពួកគេបានឃើញលោកមេឃុំប្រធានភូមិគ្រប់ភូមិក្នុងឃុំនៅផ្ទះម្ចាស់ឆ្កែរួចជាស្រេច។ ពួកគេសួរដេញដោលរកហេតុផលដែលធ្វើអោយឆ្កែជ្រួលច្របល់ មេភូមិកំហូចឆ្លើយភ្លាមថា ÷

-អាម៉ៅវាឆ្កួតហើយ

ឆ្កែទាំងអស់ឮសំដីមេភូមិ ពួកវាលូអោយទ្រហឹង ពួកវាចង់ស្រែកថាមិនសុខចិត្តទេ ចំនែកអ្នកភូមិមិនបានចាប់អារម្មណ៍នឹងសំលេងលូរបស់ឆ្កែទេ ហើយពួកគាត់ក៏មិនចង់ជឿសំដីរបស់មេឃុំដែរ តែមិនដឹងធ្វើដូចម្តេច ព្រោះគ្មានសំដីឯណាចេញពីមាត់នរណា ដែលខុសពីសំដីរបស់មេភូមិសំរាប់ពួកគាត់ស្តាប់ឡើយទើបពួកគាត់បានត្រឹមតែជឿទាំងមិនអស់ចិត្តប៉ុណ្ណោះ។

-មើលចុះនោះជាផ្ទះរបស់មេវា ខ្ញុំស្តាយមេវាណាស់មិនគួរអាម៉ៅខាំអោយស្លាប់សោះ បងប្អូនជួយមើលចានឆ្នាំងរបស់ខ្ញុំ កូនរបស់ខ្ញុំឈាមពេញខ្លួនគឺសុទ្ធតែដោយសារវាខាំទាំងអស់។

អំនះអំនាងដ៏ប៉ិនប្រសប់របស់ម្ចាស់ឆ្កែ បានធ្វើអោយអ្នកស្រុកជឿស្លុង តែឆ្កែទាំងអស់មិនសុខចិត្តឡើយពួកគេនៅតែព្រុសនៅតែលូឮទ្រហឹងដើម្បីសំដែងនូវការមិនពេញចិត្ត ពួកវារត់ស្រែកជុំវិញមេភូមិ ជុំវិញម្ចាស់ឆ្កែ មើលទៅពួកគេហាក់ដូចជាចង់ចង្អុលមុខឬបកអាក្រាតអំពើឃោរឃៅរបស់អ្នកទាំងពីរ។ ដោយមិននឹកស្មានថាមេភូមិនិងម្ចាស់ឆ្កែពិសពុលហួសនិស្ស័យ ធ្វើអោយពួកគេភ្លេចខ្លួនទៅក្បែរជនអន្ធពាលរហូតដល់ពួកនោះគ្រវែញសំនាញ់ចាប់បានពួកគេប្រាំក្បាល តែក្នុងនោះគ្មានអាម៉ៅទេ។ ម្ចាស់ឆ្កែមិនដឹងថាឆ្កែចេះស្តាប់ភាសាមនុស្សឬក៏អត់ទេ តែគាត់នៅតែគំរាមហ្វូងឆ្កែថា÷

-បើពួកឯងហ៊ានចូលអញនឹងសំលាប់ឆ្កែទាំងប្រាំនេះចោល។

ឮដូច្នេះឆ្កែទាំងអស់ក៏ដកថយ ត្បិតតែហ្វូងឆ្កែដកថយមែនតែពួកគេក៏មិនទៅណាដែរ មេភូមិខឹងខ្លាំងណាស់គាត់ស្រែកបញ្ជាភ្លាម÷

-បងប្អូនអ្នកស្រុកសំលាប់ឆ្កែភ្លាមទៅ។

អ្នកស្រុកនៅរេរាៗមិនព្រមធ្វើតាមបញ្ជាមេភូមិឡើយ ពេលនោះម្ចាស់ឆ្កែរត់ចូលក្នុងផ្ទះភ្លាម។ ចេញមកវិញបានធុងប្រេងមួយក៏លើកជះទៅលើហ្វូងឆ្កែ ហ្វូងឆ្កែដឹងថាចំនុចគ្រោះថ្នាក់មកដល់ហើយពួកគេក៏ស្ទុះសំដៅទៅខាំម្ចាស់ឆ្កែ ម្ចាស់ឆ្កែភ័យណាស់ក៏ស្រែកស្លន់ថា÷

-កើបភ្លើងក្នុងជើងក្រានជះភ្លាមទៅ! ឆ្កែឆ្កួតទាំងអស់ហើយបើមិនអញ្ចឹងទេវានឹងខាំអ្នកទាំងអស់គ្នាមិនខាន។

អណ្តាតភ្លើងបានក្លាយជាសួនអគ្គីចំពោះមុខមេភូមិនិងម្ចាស់ឆ្កែ ព្រមទាំងអ្នកដទៃជាច្រើននាក់ទៀតផងដែរ។ ស្នាមញញឹមរបស់មេភូមិនិងម្ចាស់ឆ្កែបានក្លាយជាគ្រឿងចំអកចំពោះមុខពពុះឈាមដែលឆេះខ្លោចរបស់ហ្វូងឆ្កែ។ សំលេងស្រែកទ្រហោបង្ហាញការឈឺចាប់ បានបង្កើតទៅជាបរិយាកាសគួរអោយសង្វេគចំពោះអារម្មណ៍អ្នកស្រុកទូទៅ តែវាបានក្លាយទៅជាកំលាំងចិត្តដ៏មានអនុភាពសំរាប់មេភូមិនិងម្ចាស់ឆ្កែ ពួកគេឈរញញឹមបានយ៉ាងស្រស់។ នៅពេលហ្វូងឆ្កែស្លាប់ខ្លះនិងមួយភាគទៀតរត់ខ្ចាត់ខ្ចាយអស់ មេភូមិបានធ្វើលិខិតបញ្ជាក់មួយដែលមានហត្ថលេខាមិនពេញចិត្តពេញថ្លើម

របស់ប្រជាជននិងត្រារបស់មេឃុំដោយកំណត់ថាអាម៉ៅជាឆ្កែឆ្កួត ហើយឆ្កែដែលស្លាប់ទាំងអស់សុទ្ធតែអាម៉ៅខាំអោយឆ្កួត។ ពេលនេះអាម៉ៅមិនទាន់ស្លាប់ទេ យើងត្រូវរកវិធីសំលាប់វាអោយបាន។ អ្នកស្រុកបាននាំគ្នាយកខ្នោចឆ្កែជាច្រើនចងក ហើយរ៉កឡើងលើរតផ្ទះ។ អាម៉ៅដើរសំដៅផ្ទះនោះដោយភ្នែកសំលឹងហ្វូងឆ្កែដែលត្រូវគេព្យួរកដោយទឹកមុខក្រៀមក្រំ បន្ទាប់មកវាសំលឹងទៅហ្វូងមនុស្សមិនដាក់ភ្នែក ហើយជើងរបស់វាចេះតែដើរទៅរកមេវាឥតឈប់ ទោះបីអ្នកស្រុកបានលើកអាវុធដ៏ឃោរឃៅមកវាយប្រហាលើវាឥតដាច់ក៏ដោយ។ មាត់វាមិនព្រមស្រែក ទឹកភ្នែកវាក៏មិនព្រមហូរ ឯជើងរបស់វាក៏មិនព្រមឈប់ដែរ។ អាម៉ៅក្រាបនៅលើផ្នូរមេវាយ៉ាងស្ងៀមស្ងាត់ក្នុងខណៈពេលដែលដំបងយ៉ាងប្រសេចប្រសាចកំពុងសំពងលើរាងកាយវា។ មួយសន្ទុះក្រោយមកគេក៏ស្លាប់ទាំងកែវភ្នែកជិតជាប់នូវវិប្បដិសារីយ៉ាងឈឺចាប់។

ក្រោយពីរឿងហេតុបានចប់សព្វគ្រប់អស់អ្នកស្រុកយល់ថា ត្បិតតែឆ្កែទាំងនោះឆ្កួតមែនតែយ៉ាងហោចណាស់ពីមុនមក ពួកគេមានគុណសម្បត្តិក្នុងភូមិច្រើនណាស់ ដូច្នេះគួរតែរកកន្លែងល្អកប់សពឆ្កែអោយបានស្រួលបួល។ តែម្ចាស់ឆ្កែនិងមេភូមិបែរជាមានគំនិតថា ដោយសារតែរឿងឆ្កែ ក្នុងភូមិបានជួបគ្រោះចង្រៃច្រើនណាស់ ដូច្នេះគួរតែយកសាច់ឆ្កែទាំងនេះជប់លៀងអោយជ្រះចង្រៃម្តង។ មើលឃើញថាយោបល់ខាងលើសមហេតុសមផលអ្នកស្រុកក៏យល់ព្រម។

សាច់ឆ្កែឆាញ់ណាស់ ពិសេសមេភូមិ ម្ចាស់ឆ្កែនិងក្រុមចោរសុទ្ធតែគិតថាលាភកំពុងតែជាន់លើសំណាងហើយ។

-លោកបងស្ងួម្បីតែទេវតាក៏ចង់សោយសាច់ឆ្កែដែរ ដឹងថាឆ្កែស្លាប់ដោយសារភ្លើងទេវតាឃាត់មេឃមិនអោយភ្លៀងតាំងពីពេលអ្នកស្រុកមកម្លេះ។

-លោកមេភូមិ ទោះជាទេវតាមិនជួយក៏គ្មានបញ្ហាដែរ។ បងគិតទៅមើល កាំបិត លំពែង ដាវនិងអ្វីៗជាច្រើនទៀតសុទ្ធតែនៅលើដៃមនុស្សនរណាហ៊ានមិនស្តាប់យើងហះៗៗ!

រំពេចនោះ ឆ្អឹងឆ្កែ រោមឆ្កែ និងសារពាង្គកាយទាំងអស់នៃឆ្កែបានក្លាយជាមាសយ៉ាងឆ្អិនឆ្អៅ។ ការប្រតាយប្រតប់ដណ្តើមមាសគ្នាធ្វើអោយមានមនុស្សស្លាប់រាយដូចកណ្តាប់ស្រូវ។ នៅសល់តែក្រុមចោរ មេភូមិ ម្ចាស់ឆ្កែដែលមានឱកាសស្រែកទ្រហោសប្បាយចិត្តនឹងមាសដ៏ច្រើនមហិមា។ មិនដឹងហេតុអ្វីមាសទាំងនោះបានក្លាយជាលាមកឆ្កែទាំងអស់មួយពព្រិចភ្នែក ធ្វើអោយអ្នកទាំងអស់ខកចិត្តសោកស្តាយ ស្លន់ល្វីល្វើលែងដឹងអ្វីទាំងអស់ ក៏ចេះតែស្រែកដដែលៗថា អាម៉ៅឆ្កែឆ្កួតៗរហូតទៅ។ បន្ទាប់ពីអ្នកភូមិស្លាប់អស់ទៅ ទឹកដី ទ្រព្យសម្បត្តិគ្រប់បែបយ៉ាងត្រូវអ្នកភូមិជិតខាងពុះច្រៀកដណ្តើមគ្នាអស់។

ព្រះសូរិយាថ្ងៃថ្មី ដោយហែហមពីសំណាក់ព្រះពាយនិងនភាល័យព្រមទាំងប្រព័ន្ធទាក់ទងគ្នាគ្រប់បែបយ៉ាង ធ្វើអោយព្រះអាទិត្យបាត់បង់នូវភាពឯកានឿយហត់ បែរជាមកសប្បាយចិត្តក្នុងការគ្រប់គ្រងផែនដី។ ការបែងចែកពន្លឺក៏ចំទិសដៅហើយសមល្មមនឹងតំរូវការរបស់អ្នកនៅក្រោមការគ្រប់គ្រងរបស់ខ្លួន។ ភាពរុងរឿងចំពោះអ្នកភូមិថ្មីបានកើតឡើងឥតឈប់ឈរ ជាហេតុធ្វើអោយពួកគេនឹករលឹកចំពោះឆ្កែដែលស្លាប់ទៅយ៉ាងខ្លាំងពិសេសចំពោះអាម៉ៅនិងមេរបស់វា។

ដើម្បីជាកិច្ចតបស្នងសងគុណ អ្នកភូមិបានដើរប្រមូលឆ្អឹងឆ្កែទាំងអស់មកកប់នៅទីខ្ពស់មួយដោយដាំដើមពោធិ៍ពីលើហើយអោយឈ្មោះថា « វីរបុរសមាសម៉ៅ » ហើយទុកជាសក្ការៈតទៅ៕